# ផ្ទៃរឿង រូបអង្គនៃព្រះ

**មេរៀនទី៥ រូបអង្គនៃព្រះ លោកុប្បត្តិ ១-៣**

លោកុប្បត្តិ ១:២៦ បញ្ជាក់ថា«*ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងសត្វជើង៤ ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារ ដែលវារនៅផែនដីផង*»

ខគម្ពីរនេះមានសារៈសំខាន់ណាស់ក្នុងការជួយឲ្យយើង បានយល់ដឹងអំពីមនុស្ស និងរបៀបដែលព្រះជាម្ចាស់ បានបង្កើតយើងមក។ មេរៀននេះខ្លីណាស់ក្នុងការពន្យល់ឲ្យបានក្បោះក្បាយអំពីមនុស្សនៅក្នុងខនេះ ប៉ុន្តែយើងខ្ញុំនឹងពន្យល់ដោយសង្ខេបនូវចំនុចមួយចំនួន។

បង្កើតឡើងក្នុងរូបអង្គទ្រង់ មានន័យថា ព្រះជាម្ចាស់ ទ្រង់បង្កើតយើងមកដើម្បីគ្រប់គ្រងលើរបស់សព្វសារពើ ដែលទ្រង់បានបង្កើតមក ប៉ុន្តែយើងត្រូវគ្រប់គ្រងតាមរយៈការចុះចូលចំពោះទ្រង់។ ដូច្នេះ យើងមិនមានសេរីភាពក្នុងការគ្រប់គ្រងទៅតាមបំណងប្រាថ្នាផ្ទាល់ខ្លួនឯងឡើយ ប៉ុន្តែយើងត្រូវគ្រង់គ្រង ទៅតាមបំណងព្រះហឫទ័យនៃព្រះជាម្ចាស់វិញ។




នោះមានន័យថា មនុស្សត្រូវតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រយោជន៍ដើម្បីលឺនូវអ្វីដែលទ្រង់បង្គាប់ហើយគេត្រូវស្តាប់តាម។ ហេតុដូច្នេះ ក្រោយពីព្រះជាម្ចាស់បានបង្កើតមនុស្សមក ទ្រង់អាចនិយាយទៅកាន់ពួកគេ និងប្រាប់ពួកគេ នូវអ្វីដែលគេត្រូវធ្វើ។

ដូច្នេះ នៅពេលដែល អ័ដាម និងអេវ៉ា បានស្តាប់តាម ពស់ ហើយមិនស្តាប់បង្គាប់តាមសេចក្តីបង្គាប់របស់ ព្រះជាម្ចាស់ គេមិនបានបំពេញតួនាទីក្នុងនាមជារូបអង្គនៃព្រះទេ។ ជាលទ្ធផល ដែលកើតចេញពីការបះបោរ រូបអង្គនៃព្រះក្នុងមនុស្សបានពុករលួយទៅ។ ជំនួសឲ្យការចុះចូលចំពោះព្រះ មនុស្សបែរជាបះបោរប្រឆាំងនឹងព្រះ។ យើងមាននិស្ស័យដែលលំអៀងទៅរកអំពើបាប។ សេចក្តីពន្យល់បន្ទាប់ នៅក្រោយគម្ពីរលោកុប្បត្តិ ជំពូក១ អំពីរូបអង្គទ្រង់ និង មានភាពដូចព្រះជាម្ចាស់ គឺ លោកុប្បត្តិជំពូក ៥:១-៣។ អត្ថបទនេះបង្ហាញថា អ័ដាម មានកូនប្រុសម្នាក់ «*តាមរូបភាពគាត់*»។ ដូច្នេះឥឡូវ ភាពដូចជារូបព្រះនៅក្នុងមនុស្សបានពុករលួយហើយ ដោយសារយើងត្រូវបានបង្កើតឡើងមកតាមរូបភាពនៃឪពុកម្តាយរបស់យើងដែលពេញដោយអំពើបាប។

**គម្ពីរសញ្ញាណថ្មី**

គម្ពីរសញ្ញាណថ្មីបញ្ជាក់ថា ព្រះគ្រីស្ទគឺជារូបអង្គដ៏ឥតខ្ចោះនៃព្រះជាម្ចាស់«*ដែលទ្រង់*(ព្រះគ្រីស្ទ)*ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក*» (កូល៉ុស ១:១៥)។ ព្រះគ្រីស្ទយេស៊ូវ បានបំពេញនូវអ្វីៗទាំងអស់ដែល មនុស្សត្រូវធ្វើក្នុងនាមជារូបអង្គនៃព្រះ។ ទ្រង់បានទទួលជ័យជំនះ នៅកន្លែងដែល អាដាមបានបរាជ័យ។ ព្រះគ្រីស្ទយេស៊ូវ ចុះចូលនឹងព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ គ្រប់លក្ខណ៍ ព្រមទាំងគ្រប់គ្រងលើសព្វសារពើ។ នេះគឺជាគោលការណ៍ដែលយើងមើលឃើញក្នុងគម្ពីរភីលីព ២:៥-១១។ ព្រះគ្រីស្ទយេស៊ូវ ចុះចូលនឹងព្រះវរបិតា ដែលគង់នៅនគរឋានសួគ៌ បន្ទាបខ្លួន និងសុគតលើឈើឆ្កាងទៅតាមការបង្គាប់បញ្ជារបស់ព្រះវរបិតា។ ដូច្នេះ ទ្រង់មានព្រះនាមលើអស់ទាំងព្រះនាម។ គ្រប់ទាំងជង្គង់ ត្រូវលុតនៅចំពោះទ្រង់។ ព្រោះតែទ្រង់បានចុះចូល ទ្រង់អាចគ្រប់គ្រងលើអ្វីៗទាំងអស់។ ទ្រង់គ្រប់គ្រងតាមរយៈការចុះចូល។

ព្រះគ្រីស្ទយេស៊ូវ គឺជារូបអង្គដ៏ឥតខ្ចោះនៃព្រះ ដូច្នេះ ទ្រង់ឆ្លុះបញ្ចាំងពីសិរីល្អរបស់ ព្រះអម្ចាស់និងបើកសំដែងព្រះអម្ចាស់ (ហេព្រើរ ១:៣; យ៉ូហាន ១៧:៤-៥)។ ប៉ុន្តែ ព្រះគ្រីស្ទមិនមែនគ្រាន់តែជារូបអង្គនៃព្រះដ៏ឥតខ្ចោះប៉ុណ្ណោះទេ លើសពីនេះទៅទៀតព្រះគម្ពីរសញ្ញាថ្មី ប្រកាសថា អស់អ្នកដែលនៅក្នុងព្រះគ្រីស្ទ (នោះគឺអស់អ្នកដែលជឿព្រះនាមព្រះយេស៊ូវ) គឺបានកើតជាថ្មីក្នុងរូបអង្គទ្រង់។ នៅក្នុងកូរិនថូស ទី២ ៣:១៨ លោកប៉ុលសរសេរ «*ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះ*

*វិញ្ញាណ*»។ ដូច្នេះនៅទីនេះ យើងឃើញថា អស់អ្នកដែលនៅក្នុងព្រះគ្រីស្ទកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបទ្រង់ និងដូចជាឆ្លុះបញ្ចាំងរូបនោះឯង ពីសិរីល្អរបស់ព្រះជាម្ចាស់។

តែដំណើរការនេះនៅកំពុងបន្តនៅឡើយ។ យ៉ូហាន ទី១ ៣:២ ថា«*ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក នោះ* ***យើងនឹងបានដូចជាទ្រង់*** *ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង*» ដូច្នេះ យើងនឹងបានដូចជាទ្រង់ នៅពេលដែល ព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកវិញ នោះដំណើរការ នឹងបានបញ្ចប់ពេញលេញ។ ដូច្នេះចូរយើងផ្តោតការយកចិត្តទុកដាក់ទៅលើថ្ងៃនោះ នៅពេលដែលព្រះយេស៊ូវយាងត្រឡប់មកវិញ យើងនឹងបានជារូបអង្គនៃព្រះដ៏ឥតខ្ចោះ និងដូចជាទ្រង់យ៉ាងឥតខ្ចោះ យើងនឹងចុះចូលចំពោះទ្រង់ ក្នុងនាមជាអ្នកបម្រើព្រះ និងឆ្លុះបញ្ចាំងពីសិរីល្អរបស់ទ្រង់។

ដូច្នេះម្តងទៀត តាមរយៈន័យ*រូបអង្គទ្រង់* យើងឃើញពីរចនាសម្ព័ន្ធនៃព្រះគម្ពីរ គឺលោកុប្បត្តិ ១-៣ ចងភ្ជាប់គ្នាយ៉ាងស្អិតរមួតជាមួយវិវរណៈ ២០-២២ ហើយព្រះគ្រីស្ទគឺជាខ្សែអំបោះដែលចងភ្ជាប់ព្រះគម្ពីរទាំងមូល។ ដូច្នេះ គម្ពីរលោកុប្បត្តិ ១:២៦-២៨ មានអ្វីៗជាច្រើនក្នុងការបង្រៀនយើងអំពីមនុស្សជាទូទៅ (ច្រើនជាងអ្វីដែលមានបង្រៀននៅទីនេះ) ការអនុវត្តជាសំខាន់គឺថាព្រះគ្រីស្ទគឺជារូបអង្គទ្រង់ដ៏ពិត ហើយតាមរយៈការជឿដំណឹងល្អនៃព្រះគ្រីស្ទ នោះមនុស្សអាចប្រែទៅជាថ្មីក្នុងរូបអង្គរបស់ព្រះជាម្ចាស់។ ដូច្នេះ យើងគួរតែប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ទ ដើម្បីឲ្យតាមរយៈសេចក្តីជំនឿ គេអាចផ្លាស់ប្រែទៅ ឱ្យដូចជារូបទ្រង់ និងសំឡឹងទៅមុខដោយសេចក្តីសង្ឃឹម ដល់ថ្ងៃដែលព្រះគ្រីស្ទទ្រង់យាងត្រឡប់មកវិញ នៅពេលយើងបានផ្លាស់ប្រែទៅ ឱ្យដូចជារូបទ្រង់ពេញខ្នាត។

## រចនាសម្ព័ន្ធនៃព្រះគម្ពីរ

## ការបង្កើត → ព្រះយេស៊ូវ → ការបង្កើតថ្មី

